# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង
## ស្តីអំពីពិព័រណ៍ការងារ និងផលិតភាព សៀមរាប ឆ្នាំ២០១៩
## ថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩
## នៅសួនច្បារព្រះអង្គចេក ព្រះអង្គចម

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ក្រសួង មន្ទីរ ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារធ្វើ សិស្ស និស្សិត ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងសាធារណជនមេត្តាជ្រាបថា ពិព័រណ៍ការងារ និងផលិតភាព សៀមរាប ឆ្នាំ២០១៩ (Career and Productivity Fair-Siem Reap 2019) នឹងត្រូវបានរៀបចំចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ ពីម៉ោង ០៨:០០ នាទីព្រឹក ដល់ម៉ោង ២០:០០ នាទីយប់ នៅសួនច្បារព្រះអង្គចេក ព្រះអង្គចម ក្រោមការគាំទ្ររបស់សាលាខេត្តសៀមរាប សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តសៀមរាប (ស.ស.យ.ក) និងអង្គការអន្តរជាតិខាងការងារ (ILO) ។ ព្រឹត្តិការណ៍ការងារដ៏ធំជាងគេបំផុតនៅខេត្តសៀមរាបនេះរៀបចំឡើងក្នុងគោលបំណងដើម្បីៈ

- បង្កើតជាវេទិកាការងារដ៏ធំនៅមួយកន្លែងដោយងាយស្រួល សម្រាប់និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអ្នកស្វែងរកការងារធ្វើ សំដៅតាំងបង្ហាញ ធ្វើការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានទីផ្សារការងារ លើកកម្ពស់ការយល់ដឹង និងបណ្តុះគំនិតអំពីការបង្កើនផលិតភាព។
- និយោជកអាចធ្វើការផ្សព្វផ្សាយពីតម្រូវការជ្រើសរើសកម្លាំងពលកម្មនាពេលបច្ចុប្បន្ន និងអនាគត ដើម្បីទាក់ទាញអ្នកស្វែងរកការងារធ្វើដែលមានសមត្ថភាព។
- អ្នកស្វែងរកការងារធ្វើអាចដាក់ពាក្យរកការងារនៅនឹងកន្លែងផ្ទាល់ ព្រមទាំងទទួលបានព័ត៌មានអំពីឱកាសការងារនាពេលបច្ចុប្បន្ន និងអនាគតព្រមទាំងឱកាសក្នុងការអភិវឌ្ឍជំនាញនានា។
- អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលអាចផ្សព្វផ្សាយកម្មវិធីសិក្សា វគ្គសិក្សា និងកម្មវិធីអភិវឌ្ឍជំនាញគ្រប់ប្រភេទ។
- ពង្រីកបណ្តាញទំនាក់ទំនងផ្នែកធនធានមនុស្ស។
- ចូលរួម "អបអរសាទរខួប១០០ឆ្នាំនៃអង្គការអន្តរជាតិខាងការងារ (ILO) និងខួប៥០ឆ្នាំនៃសមាជិកភាពកម្ពុជាក្នុងអង្គការ ILO"។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ដែលមានបំណងចូលរួមតាំងបង្ហាញស្លាកសញ្ញា ឱកាសការងារ និងជ្រើសរើសកម្លាំងពលកម្ម សូមទាក់ទងសួរព័ត៌មានលម្អិតមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខទូរស័ព្ទ **០១៧ ៨៧១ ៨០៧** ឬចូលមើលគេហទំព័រ **www.pcf.nea.gov.kh**។ បន្ថែមលើនេះ អ្នកស្វែងរកការងារ សិស្ស និស្សិត និងសាធារណជន សូមអញ្ជើញចូលទស្សនា និងដាក់ពាក្យរកការងារឱ្យបានច្រើនកុះករ។

ថ្ងៃ ពុធ ៦កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩